DEPARTMENT OF
Education
STATE OF MAINE

# រាបាយការណ៍វាយតម្លៃពីអសមត្ថភាពក្នុងការសិក្សា

បទបញ្ញត្តិអប់រំពិសេសយូនីហ្វាយរបស់រដ្ឋមេអ៊ីន (Maine Unified Special Education Regulations) [MUSER] VII.2.L

**ការដាក់ឱ្យនៅ SAU / សាលា / ថ្នាក់ ឬ CDS :**

**កាលបរិច្ឆេទប្រជុំ :**

ឈ្មោះកុមារ :
ថ្ងៃ.ខែ.ឆ្នាំកំណើត/អាយុ :
ព័ត៌មានឪពុកម្តាយ :
អ្នកគ្រប់គ្រងសំណុំរឿង :

**<u>និយមន័យនៃអសមត្ថភាពក្នុងការសិក្សាជាក់លាក់ :</u>** <u>MUSER VII.2.L</u>

ពាក្យនេះមានន័យថាជា បញ្ហាមួយ ឬច្រើននៅក្នុងដំណើរការផ្នែកផ្លូវចិត្តមូលដ្ឋាន ដែលទាក់ទងជាមួយនឹងការយល់ ឬ ការប្រើប្រាស់ភាសា និយាយ ឬ សរសេរ ដែលអាចបញ្ជាក់ឱ្យឃើញពីសមត្ថភាពមិនគ្រប់គ្រាន់ក្នុងការស្តាប់ គិត និយាយ អាន ប្រកប ឬ ការគណនាលេខ រួមបញ្ចូលទាំងលក្ខខណ្ឌដូចជា អសមត្ថភាពផ្នែកសតិបញ្ញា របួសខួរក្បាល វិកលផ្នែកខួរក្បាលតូចបំផុត វិកលទស្សន៍ និង ការនិយាយមិនរួចដែលកើនឡើងជាលំដាប់ ។ អសមត្ថភាពក្នុងការសិក្សាជាក់លាក់ មិនរួមបញ្ចូលបញ្ហានៃការសិក្សាដែលបណ្តាលជាមូលដ្ឋានមកពីអសមត្ថភាពក្នុងការមើល ការស្តាប់ ឬ អសមត្ថភាពផ្នែកផ្លូវចិត្ត ឬ ការលូតលាស់ប្រាជ្ញាស្មារតីយឺត ឬ ការរំខានផ្លូវចិត្ត ឬ ការពិបាកផ្នែកបរិស្ថាន វប្បធម៌ ឬ សេដ្ឋកិច្ចឡើយ ។

**<u>ផ្នែក ក : លក្ខណៈ</u>**

| | | |
|---|---|---|
| **1. តើមានបញ្ហានៅក្នុងដំណើរការផ្នែកផ្លូវចិត្តមូលដ្ឋានមួយ ឬ ច្រើនដូចបានបង្ហាញដោយ** MUSER VII.2.L.(2)(ii) **ណាមួយដែរឬទេ ?**<br><br>**a. ការប្រែប្រួលតាមបទដ្ឋាន 1.5 នៅក្រោមមធ្យមនៅក្នុងផ្នែកយ៉ាងហោចមួយនៃដំណើរការផ្នែកផ្លូវចិត្ត** MUSER VII.2.L.(2)(ii)<br><br>**ឬ**<br><br>**b. ការប្រែប្រួលតាមបទដ្ឋាន 1 នៅក្រោមមធ្យមនៅក្នុងផ្នែក 2 ឬ ច្រើនជាងនេះ ។** MUSER VII.2.L.(2)(ii) | **បាទ-ចាំ** | **ទេ** |
| ផ្ទៀងផ្ទាត់ពិន្ទុ (ដូចជា អង្គចងចាំដំណើរការ អង្គចងចាំរយៈពេលយូរ អង្គចងចាំរយៈពេលខ្លី ដំណើរការស្តាប់សម្លេង ការមើលរូបភាពក្នុងលំហ ដំណើរការសំនៀងសូរស័ព្ទ ការយកទាញយកចំណេះមកប្រើ និង ល្បឿននៃដំណើរការ) : | | |

| | | | |
|---|---|---|---|
| **2. <u>សម្រាប់សិស្សថ្នាក់ទី 4-12</u> តើសិស្សទទួលបានពិន្ទុតាមបទដ្ឋានផ្សំ មិនទាបជាងការប្រែប្រួលតាមបទដ្ឋាន 1.5 នៅក្រោមមធ្យមដែលយ៉ាងហោចមានសន្ទស្សន៍ ឬ មាត្រដ្ឋាននៃមុខងារយល់ដឹងមួយដែរឬទេ ?** MUSER VII.2.L.(2)(iii) | **បាទ-ចាំ** | **ទេ** | **មិនដឹង** |
| **ផ្ទៀងផ្ទាត់ពិន្ទុ :** | | | |

*<u>សម្រាប់សិស្សថ្នាក់មត្តេយ្យ-**3 :**</u>*

*ប្រសិនបើសំណួរទី **1** ត្រូវបានឆ្លើយថា "បាទ-ចាំ" សូមបន្តទៀត ។ ប្រសិនបើសំណួរទី **1** ត្រូវបានឆ្លើយថា "ទេ" នោះសិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។*

*<u>សម្រាប់សិស្សថ្នាក់ទី **4-12 :**</u>*

*ប្រសិនបើសំណួរទី **1** <u>និង</u> ទី **2** ត្រូវបានឆ្លើយថា "បាទ-ចាំ" សូមបន្តទៀត ។ ប្រសិនបើសំណួរទី **1** ឬទី **2** ត្រូវបានឆ្លើយថា "ទេ" នោះសិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។*

| **3.** តើសិស្សមានអាយុគ្រប់គ្រាន់ ឬ បំពេញបានតាមបទដ្ឋានកម្រិតថ្នាក់ដែលអនុម័តដោយរដ្ឋនៅក្នុងចំណុចទាំងឡាយខាងក្រោម នៅពេលត្រូវបានផ្តល់ឱ្យនូវបទពិសោធន៍សិក្សា និង ការណែនាំសមស្របតាមអាយុរបស់សិស្ស ឬ បទដ្ឋានកម្រិតថ្នាក់អនុម័តដោយរដ្ឋដែរឬទេ ?<br>MUSER VII.2.L.(2)(c)(I) | បាទ-ចាំ | ទេ |
|---|---|---|
| ប្រសិនបើមិនមាន ចូរបង្ហាញពីលក្ខណៈដែលសិស្សមិនមាន :<br><br>___ សំនួនសេចក្តីផ្ទាល់មាត់ ___ ភាពស្ទាត់ជំនាញក្នុងការអាន<br>___ ចំណេះដឹងក្នុងការស្តាប់ ___ ចំណេះដឹងក្នុងការអាន<br>___ សំនួនសេចក្តីសរសេរ ___ ការគណនាគណិត<br>___ ជំនាញអានមូលដ្ឋាន ___ ដំណោះស្រាយចំណោទគណិតវិទ្យា<br><br>ផ្ទៀងផ្ទាត់ : | | |

*ប្រសិនបើសំណួរទី **3** ត្រូវបានឆ្លើយថា "ទេ" សូមបន្តទៀត ។ ប្រសិនបើសំណួរទី **3** ត្រូវបានឆ្លើយថា "បាទ-ចាំ" នោះសិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។*

| **4. a.** តើសិស្សមិនទាន់ដល់អាយុ ឬ មិនមានបទដ្ឋានកម្រិតថ្នាក់ដែលអនុម័តដោយរដ្ឋនៅក្នុងចំណុចមួយ ឬ ច្រើនជាងនេះដែលបង្ហាញនៅក្នុងសំណួរទី **3** នៅពេលប្រើប្រាស់ដំណើរការអាស្រ័យទៅតាមការឆ្លើយតបរបស់សិស្ស ចំពោះអន្តរាគមន៍ផ្អែកតាមការស្រាវជ្រាវបែបវិទ្យាសាស្ត្រ **(RTI)** ដែរឬទេ ? MUSER VII.2.L.(2)(c)(II)<br><br>ឬ<br><br>**b.** តើសិស្សបង្ហាញពីគំរូចំណុចខ្លាំង និង ចំណុចខ្សោយនៅក្នុងការប្រតិបត្តិ សមិទ្ធិផល ឬ ទាំងពីរដែលទាក់ទងជាមួយនឹងអាយុ បទដ្ឋានកម្រិតថ្នាក់ដែលអនុម័តដោយរដ្ឋ ឬ ការអភិវឌ្ឍបញ្ញាដែលកំណត់ដោយក្រុមការងារ **IEP** ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណនៃអសមត្ថភាពក្នុងការសិក្សាជាក់លាក់ ដោយប្រើប្រាស់ការវាយតម្លៃសមស្របដែរឬទេ ? MUSER VII.2.L.(2)(c)(II) | បាទ-ចាំ | ទេ | មិនដឹង |
|---|---|---|---|
| ផ្ទៀងផ្ទាត់ : | | | |

*ប្រសិនបើសំណួរទី **4a** ឬ **4b** ត្រូវបានឆ្លើយថា "ទេ" សូមបន្តទៀត ។ បើពុំនោះទេ សិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។*

| **5.** តើការមិនបានសម្រេចដូចបានកំណត់ ដោយសារតែខ្វះការណែនាំសមស្របនៅក្នុងការអាន ឬ គណិតវិទ្យាដែរឬទេ ? MUSER VII.2.L.(2)(c)(ii) | បាទ-ចាំ | ទេ |
|---|---|---|
| *<u>នៅក្នុងការធ្វើការកំណត់នេះ ក្រុមការងារត្រូវតែពិចារណាពី :</u>*<br>*a) ទិន្នន័យដែលបង្ហាញថា មុន ឬ ជាផ្នែកមួយនៃដំណើរការបញ្ជូនមក កុមារត្រូវបានផ្តល់ការណែនាំសមស្របនៅក្នុងក្របខណ្ឌការអប់រំជាទៀងទាត់ ផ្តល់ដោយបុគ្គលិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ <u>និង</u>* MUSER VII.2.L.(2)(c)(I)<br>*b) ឯកសារផ្អែកតាមទិន្នន័យនៃការវាយតម្លៃដដែលៗនៃសមិទ្ធិផលតាមចន្លោះពេលសមស្រប ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃផ្លូវការនៃការរីកចម្រើនរបស់សិស្សក្នុងអំឡុងពេលការណែនាំ ដែលត្រូវបានផ្តល់ឱ្យឪពុកម្តាយរបស់កុមារ ។* MUSER VII.2.L.(2)(c)(II) | | |

***ប្រសិនបើសំណួរទី 5 ត្រូវបានឆ្លើយថា "ទេ" សូមបន្តទៀត ។ ប្រសិនបើសំណួរទី ៥ ត្រូវបានឆ្លើយថា "បាទ-ចាំ" នោះសិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។***

| **6.** អាកប្បកិរិយាពាក់ព័ន្ធដែលបានកត់ត្រាក្នុងអំឡុងពេលធ្វើការអង្កេតទាំងឡាយ និង ទំនាក់ទំនងរបស់វាចំពោះមុខងារនៃការសិក្សា : MUSER VII.2.L.(2)(e)(III) |
|---|
| |
| *កុមារត្រូវបានអង្កេតនៅក្នុងបរិយាកាសសិក្សា (រួមបញ្ចូលទាំងក្របខណ្ឌនៅក្នុងថ្នាក់រៀនជាប្រចាំ) ដើម្បីផ្តល់ឯកសារពីសកម្មភាពសិក្សា និង អាកប្បកិរិយារបស់កុមារនៅក្នុងចំណុចលំបាកនានា ។* MUSER VII.2.L.(2)(d)(i) |

| **7.** លទ្ធផលសុខភាពទាក់ទងនឹងការអប់រំ :<br>MUSER VII.2.L.(2)(e)(IV) | បាទ-ចាំ | ទេ |
|---|---|---|
| ប្រសិនបើ បាទ-ចាំ សូមបង្ហាញ : | | |

| **8.** តើការមិនទទួលបានសមិទ្ធិផលរបស់សិស្សបណ្តាលមកពី : | | |
|---|---|---|
| **a.** អសមត្ថភាពក្នុងការមើល ស្តាប់ ឬ អសមត្ថភាពផ្នែកផ្លូវចិត្ត<br>MUSER VII.2.L.(2)(e)(VI) | បាទ-ចាំ | ទេ |
| ផ្ទៀងផ្ទាត់ : | | |
| **b.** ការលូតលាស់បញ្ញាស្មារតីយឺត<br>MUSER VII.2.L.(2)(e)(VI) | បាទ-ចាំ | ទេ |
| ផ្ទៀងផ្ទាត់ : | | |
| **c.** ការរំខានផ្លូវចិត្ត :<br>MUSER VII.2.L.(2)(e)(VI) | បាទ-ចាំ | ទេ |
| ផ្ទៀងផ្ទាត់ : | | |
| **d.** ការពិបាកផ្នែកបរិស្ថាន វប្បធម៌ ឬ សេដ្ឋកិច្ច និង/ឬ ភាពស្ទាត់ជំនាញភាសាអង់គ្លេសមានកំណត់<br>MUSER VII.2.L.(2)(e)(VI) | បាទ-ចាំ | ទេ |
| ផ្ទៀងផ្ទាត់ : | | |

***ប្រសិនបើសំណួរទី 8 a-d ត្រូវបានឆ្លើយថា "ទេ" សូមបន្តទៀត ។ ប្រសិនបើផ្នែកណាមួយនៅក្នុងសំណួរទី 8 ត្រូវបានឆ្លើយថា "បាទ-ចាស" នោះសិស្សមិនមានលក្ខណៈសម្បត្តិទទួលបានការអប់រំពិសេសក្នុងលក្ខណៈជាសិស្សម្នាក់ដែលអសមត្ថភាពក្នុងការសិក្សានោះទេ ។ សូមរំលងទៅ "ការសន្និដ្ឋាន" ។***

| **9.** តើការវាយតម្លៃត្រូវបានប្រើជាការវាយតម្លៃដែលយកជាការ និង ទុកចិត្តបាន និង ធ្វើឡើងដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ ?<br>V.2.C.(1)(c)&(d) | បាទ-ចាំ | ទេ |
|---|---|---|

<u>ផ្នែក ខ : ការសន្និដ្ឋាន</u>

| **1.** តើអសមត្ថភាពក្នុងការសិក្សាកើតឡើងដែរឬទេ ? MUSER VII.2.L.(2)(e)(I) | បាទ-ចាំ | ទេ |
| --- | --- | --- |
| ចូរសង្ខេបពីមូលដ្ឋានសម្រាប់ការសម្រេចចិត្ត : | | |

*ប្រសិនបើចម្លើយចំពោះសំណួរទី **1** គឺ "បាទ-ចាំ" សូមបន្តទៅកាន់សំណួរទី **2** ។ ប្រសិនបើចម្លើយគឺ "ទេ" សមាជិកក្រុមការងារ ត្រូវបញ្ជាក់អះអាងពីការយល់ព្រម ឬ មិនយល់ព្រម តាមការកំណត់នេះដោយចុះហត្ថលេខាខាងក្រោម ។*

| **2.** ប្រសិនបើមានអសមត្ថភាពក្នុងការសិក្សា តើកុមារចាំបាច់ត្រូវទទួលការអប់រំពិសេស និង សេវាពាក់ព័ន្ធដោយសារតែអសមត្ថភាពនេះដែរឬទេ ? MUSER V.2.F.(2) | បាទ-ចាំ | ទេ |
| --- | --- | --- |
| ផ្ទៀងផ្ទាត់ : | | |

*ប្រសិនបើចម្លើយចំពោះសំណួរទី **2** គឺ "បាទ-ចាំ" នោះសិស្សមានលក្ខណៈសម្បត្តិទទួលបានក្នុងឋានៈជាក្មេងម្នាក់ដែលអសមត្ថភាព នៅក្រោមបទបញ្ញត្តិការអប់រំពិសេសឯកភាពរដ្ឋមេអ៊ីន **(Maine Unified Special Education Regulations)** ។ សមាជិកក្រុមការងារ ត្រូវបញ្ជាក់អះអាងពីការយល់ព្រម និង មិនយល់ព្រមរបស់ពួកគេដោយចុះហត្ថលេខាខាងក្រោម ។*

ខ្ញុំសូមបញ្ជាក់ថា របាយការណ៍នេះឆ្លុះបញ្ចាំងពីការសន្និដ្ឋានរបស់ខ្ញុំ : MUSER VII.2.L.(2)(e)(ii)

| ឈ្មោះ | មុខតំណែង |
| --- | --- |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

ខ្ញុំសូមបញ្ជាក់ថា របាយការណ៍នេះមិនឆ្លុះបញ្ចាំងពីការសន្និដ្ឋានរបស់ខ្ញុំទេ ។ MUSER VII.2.L.(2)(e)(ii)

| ឈ្មោះ | មុខតំណែង |
| --- | --- |
| | |
| | |
| | |
| | |

សមាជិកជំទាស់ត្រូវប្រគល់របាយការណ៍ដាច់ដោយឡែកមួយទៀត ។ MUSER VII.2.L.(2)(e)(ii)

កែប្រែឡើងវិញនៅថ្ងៃទី **09/02/2008**